មជ្ឈមណ្ឌលឯកសារកម្ពុជា

# សំណើសុំការព្រមានចំពោះក្រុមមេធាវីការពារក្តី ជនជាប់ចោទ ខៀវ សំផន

*បន្ទាប់ពីមានការព្រមានពីអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំពោះមេធាវី អាថឺ វែរកិន ជាមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ថាមានអកប្បកិរិយាក្រអើតក្រទម និងមានចរិតរំខានដល់កិច្ចដំណើរការនីតិវិធីសវនាការ (ចុះផ្សាយថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៣ ក្នុងកាសែតរស្មីកម្ពុជា) នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ តារីក អាប់ឌុលហាក់ បានស្នើអង្គជំនុំជម្រះសាលាដំបូងធ្វើការព្រមានជាថ្មីម្តងទៀតចំពោះក្រុមមេធាវីការពារក្តី ខៀវ សំផន រួមមាន មេធាវី គង់ សំអុន, អានតា ហ្គីសេ្ស និង អាថឺ វែរកិន អំពីចេតនាជ្រៀតជ្រែកចូលកិច្ចដំណើរការស្វែងរកយុត្តិធម៌របស់តុលាការ ។ សំណើនេះត្រូវបានធ្វើភ្លាមៗ បន្ទាប់ពីកាសែតភ្នំពេញប៉ុស្តិ៍បានចុះផ្សាយ ការរិះគន់ និងការចោទប្រកាន់ របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន អំពីកិច្ចដំណើរការរបស់អង្គជំនុំជម្រះសាលាដំបូង ។ តារីក អាប់ឌុលហាក់ បានបដិសេធចោលទាំងស្រុងចំពោះខ្លឹមសារដែលត្រូវបានចុះផ្សាយនោះ ដោយអះអាងថា ជាការចោទប្រកាន់ពុំត្រឹមត្រូវ នាំឲ្យសាធារណជនមានការភាន់ច្រឡំនិងនាំឲ្យមានភាពប្រទូស្តសារ៉ាយក្នុងកិច្ចដំណើរការរបស់អង្គជំនុំជម្រះ ។ តារីក អាប់ឌុលហាក់ បានសង្កត់ធ្ងន់ថា ទង្វើបែបនេះគឺជាការជ្រៀតជ្រែកចូលក្នុងកិច្ចដំណើរការស្វែងរកយុត្តិធម៌ ហើយក្របខណ្ឌសីលធម៌ការងាររបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន គឺធ្លាក់ចុះក្រោមបទដ្ឋានគំរូនៃការគោរពវិជ្ជាជីវៈ ដែលមេធាវីនានាត្រូវប្រកាន់យកនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ តារីក អាប់ឌុលហាក់ បានធ្វើការដកស្រង់ការចោទប្រកាន់ទាំងនោះ ហើយធ្វើការឆ្លើយតបមួយចំណុចម្តងៗដូចខាងក្រោម៖*

*ទី១) ក្រុមមេធាវីបានចោទប្រកាន់ថា “អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សី និងបានទទួលយកភស្តុតាងឯកសាររាប់ពាន់ ប៉ុន្តែបានច្រានចោលនូវការព្រួយបារម្ភនានាដែលលើកឡើងដោយក្រុមមេធាវីការពារក្តី” ។ តារីក អាប់ឌុលហាក់ អះអាងថា នេះគឺជាការលើកឡើងខុសបើធៀបទៅនឹងអ្វីដែលបានកើតឡើងនៅក្នុងសវនាការ ។ រាល់ពេលទាំងអស់ មេធាវីការពារក្តីទទួលបានឱកាសតទល់ជាមួយតំណាងសហព្រះរាជអាជ្ញា និងតទល់ជាមួយភស្តុតាងឯកសារនានា ហើយក៏មានឱកាសដាក់ឯកសារភស្តុតាងតបវិញដែរ ។ ពេលឱកាសដែលតំណាងសហព្រះរាជអាជ្ញាមាន មេធាវីការពារក្តីក៏មានដូចគ្នា ។ ជាក់ស្តែង សវនាការស្តាប់សក្ខីកម្មរបស់សាក្សីមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រុមមេធាវីការពារក្តីមានសិទ្ធិសួរដេញដោលអំពីភាពអាចជឿទុកចិត្តបាននៃឯកសារដែលទទួលបានមកពីមជ្ឈមណ្ឌលនេះ ។ ចំពោះការចោទប្រកាន់ថា ការព្រួយបារម្ភរបស់ក្រុមមេធាវីការពារក្តីត្រូវបានច្រានចោល គឺពុំត្រឹមត្រូវ*

ឡើយ ហើយខុសនឹងអ្វីដែលក្រុមមេធាវីការពារក្តីធ្លាប់បានធ្វើ ។ មេធាវីការពារក្តីមានឱកាសឆ្លើយតបចំពោះសក្ខីកម្មរបស់សាក្សី និងភស្តុតាងដែលបានដាក់ចំពោះមុខភាគី ។ ពោលគឺពុំមានភាគីណាម្នាក់ត្រូវបានអង្គជំនុំជម្រះរារាំង ឬ ច្រានចោលចំពោះការព្រួយបារម្ភណាមួយដោយពុំមានហេតុផលឡើយ ។ អង្គជំនុំជម្រះធ្លាប់ច្រានចោលសំណើសុំដាក់ឯកសារភស្តុតាងរបស់តំណាងសហព្រះរាជអាជ្ញា ដែលបានមកពីអង្គការលើកលែងទោសអន្តរជាតិ សាទូរលេខរបស់សហរដ្ឋអាមេរិកមុនឆ្នាំ ១៩៧៥ និងសក្ខីកម្មរបស់សាក្សី មាស វឿន ។

ទី២) ក្រុមមេធាវីការពារក្តីចោទប្រកាន់ថា «អង្គជំនុំជម្រះបដិសេធមិនឲ្យធ្វើការពិភាក្សាដាក់ស្តែងទៅលើភស្តុតាងជាច្រើនដែលបានទទួលយក» ។ តារីក អាប់ឌុលហាក់ អះអាងថា ការលើកឡើងបែបនេះ នឹងធ្វើឲ្យសាធារណជនមានការងឿងឆ្ងល់ ហើយនឹងមានសំណួរថាតើក្រុមមេធាវីការពារក្តី ខៀវ សំផន បានធ្វើការងារស្របតាមភាពជាក់ស្តែងដែរឬទេ ។ តារីក អាប់ឌុលហាក់ បញ្ជាក់ថា នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្តីស្នើសុំដាក់ឯកសារភស្តុតាងគន្លឹះ ហើយមេធាវីស្នើសុំមិនឆ្លើយតប ។ នៅក្នុងសវនាការ ចៅក្រុម ហ្សង់ម៉ាក ឡាវែញ បានសួរ មេធាវី អាថឺ វែរកិន ថាតើចង់ឆ្លើយតប និង យកឱកាសដែលផ្តល់ដោយអង្គជំនុំជម្រះ ធ្វើការឆ្លើយតបនឹងឯកសារគន្លឹះដែលដាក់ដោយតំណាងសហព្រះរាជអាជ្ញាដែរឬទេ? ប៉ុន្តែក្រុមមេធាវីការពារក្តី ខៀវ សំផន បានបដិសេធចំពោះឱកាសដែលផ្តល់ជូននេះ ។ មេធាវីការពារក្តីធ្វើឲ្យសាធារណជនយល់ខុសថាខ្លួនពុំមានឱកាសឆ្លើយតប ប៉ុន្តែការពិត មេធាវីការពារក្តីខ្លួនឯងជាអ្នកខកខាន ដោយពុំទទួលយកឱកាសឆ្លើយតបលើឯកសារទាំងនោះ ។ ការអះអាងរបស់ក្រុមមេធាវីការពារក្តីគឺគ្រាន់តែជាការខឹងទៅនឹងតុលាការតែប៉ុណ្ណោះ ។

ទី៣) ពាក់ព័ន្ធនឹងការបំបែកសំណុំរឿង ក្រុមមេធាវីការពារក្តីបានលើកឡើងថា «នៅពេលដែលរារាំងមេធាវីការពារក្តីមិនឲ្យពិភាក្សាលើភស្តុតាងដែលត្រូវដាក់ក្នុងសំណុំរឿងនៅដំណាក់កាលទី១ ដែលពាក់ព័ន្ធទៅនឹងគោលនយោបាយនៃការជម្លៀស អង្គជំនុំជម្រះដែលគួរឲ្យភ្ញាក់ផ្អើលនោះ គឺប្រកាសថាអង្គជំនុំជម្រះនឹងធ្វើការវិនិច្ឆ័យនៅក្នុងតំណាក់កាលទី១ អំពីការទទួលខុសត្រូវរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងគោលនយោបាយឧក្រិដ្ឋទាំងអស់ ។ ការធ្វើដូច្នេះ គឺជាការរារាំងដល់ការងាររបស់ក្រុមមេធាវីការពារក្តី» ។ តារីក អាប់ឌុលហាក់ បានលើកឡើងថា វិសាលភាពនៃអង្គហេតុនេះត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងដីកាបំបែកសំណុំរឿងដែលបានចេញក្នុងឆ្នាំ២០១១ ហើយមេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់យ៉ាងច្បាស់ថាខ្លួនបានយល់អំពីវិសាលភាពនៃដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះ ។ ប៉ុន្តែទើបមកដល់ពេលនេះលើកឡើងថា ការធ្វើបែបនេះធ្វើឲ្យខ្លួនមានការភាន់ច្រឡំលើបញ្ហានេះ និងជាការរារាំងដល់ការងាររបស់ក្រុមមេធាវីការពារក្តី ។

ទី៤) ក្រុមមេធាវីការពារក្តីចោទប្រកាន់ថា “*អង្គជំនុំជម្រះមិនដែលចាប់អារម្មណ៍ក្នុងការស្តាប់ចំពោះការលើកឡើងរបស់ក្រុមមេធាវីការពារក្តីនោះទេ*” តារីក អាប់ឌុលហាក់ អះអាងថា ការលើកឡើងនេះគឺមានការខុសទាំងស្រុង ។ មេធាវីការពារក្តីទទួលបានពេលវេលាស្មើគ្នាក្នុងការសួរដេញដោលសាក្សី និងមានឱកាសស្នើសុំសាក្សីរបស់ខ្លួន ហើយអង្គជំនុំជម្រះក៏បានកោះហៅសាក្សីទាំងនោះដែរ ។ លើសពីនេះទៀត ក្រុមមេធាវីមានការឱកាសបង្ហាញឯកសារ ប៉ុន្តែបដិសេធក្នុងការឆ្លើយតបចំពោះការបង្ហាញឯកសារ ។ ដូច្នេះមេធាវីការពារក្តីពុំដែលតវ៉ាចំពោះចំណុចសារធាតុដែលបានជំនុំជម្រះ ទើបតែមកដល់ដំណាក់កាលចុងបញ្ចប់នៃសវនាការទើបមានការលើកឡើង ។

ទី៥) ពាក់ព័ន្ធនឹងកាលៈទេសៈដែលនាំឲ្យ ខៀវ សំផន សម្រេចចិត្តនៅស្ងៀមមិនឆ្លើយតបសំណួរក្រុមមេធាវីការពារក្តីចោទប្រកាន់ថា “*អង្គជំនុំជម្រះបានបដិសេធចោលនូវសំណើសុំរបស់ ខៀវ សំផន ទាំងអស់...*” ។ តារីក អាប់ឌុលហាក់ ឆ្លើយតបថា ការលើកឡើងនេះ គឺមិនពិតឡើយ ។ អង្គជំនុំជម្រះបានទទួលយកសំណើសុំមួយចំនួន ហើយបដិសេធចោលខ្លះ ។ នៅពេល ខៀវ សំផន ប្រកាសមិនឆ្លើយតបសំណួរ អង្គជំនុំជម្រះបានស្នើឲ្យភាគីផ្តល់អានុសាសន៍អំពីបញ្ហានេះ ហើយដើម្បីជាការសម្របសម្រួលតំណាងសហព្រះរាជអាជ្ញាបានផ្តល់នូវបញ្ជីប្រធានបទសំណួរ ដើម្បីឲ្យជនជាប់ចោទពិនិត្យមុននឹងឆ្លើយ ។

តារីក អាប់ឌុលហាក់ បានធ្វើការសន្និដ្ឋានថា ការនិយាយមិនពិត និងការធ្វើឲ្យមានការយល់ខុសទៅលើកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ មេធាវីការពារក្តី ខៀវ សំផន មានចេតនាជ្រៀតជ្រែកចូលកិច្ចដំណើរការស្វែងរកយុត្តិធម៌ ។ ការអនុវត្តនេះ គឺនៅឆ្ងាយពីបទដ្ឋានវិជ្ជាជីវៈ ។ សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិស្តីអំពីគោលការណ៍ជាមូលដ្ឋានដែលត្រូវអនុវត្តចំពោះគ្រប់ភាគីទាំងអស់នៅក្នុងបន្ទប់សវនាការត្រង់មាត្រា ១២ ចែងថា “*មេធាវីគ្រប់ពេលទាំងអស់ត្រូវរក្សានូវសេចក្តីស្មោះត្រង់និងសុចរិតភាពនៃវិជ្ជាជីវៈរបស់ខ្លួន និងចូលរួមក្នុងការចាត់ចែងរដ្ឋបាលតុលាការ*” មាត្រា១៤ ចែងបន្ថែមថា “*ក្នុងការការពារកូនក្តីរបស់ខ្លួន មេធាវីត្រូវតែបំពេញការងារដោយខស្សរាព្យាយាមគ្រប់ពេលវេលានិងទទួលស្គាល់នូវក្រមសីលធម៌វិជ្ជាជីវៈ ដោយអនុលោមទៅតាមមាត្រា ២៣ នៃក្រមវិជ្ជាជីវៈដែលអនុវត្តនៅពេលដែលមេធាវីការពារក្តីចូលរួមកិច្ចការសាធារណៈ ដូចជាការពិភាក្សាអំពីការចាត់ចែងកិច្ចការរដ្ឋបាលយុត្តិធម៌ជាដើម*” ។ ការណ៍ដែលបង្ហាញអំពីអង្គហេតុមិនពិត ដែលធ្វើឲ្យសាធារណជនយល់ខុស គឺធ្វើឲ្យកិច្ចដំណើរការនីតិវិធីនៅចំពោះមុខជំនុំជម្រះធ្លាក់ទៅក្នុងការប្រទូស្តសារ៉ាយជាមួយនឹងគ្នា ។ នេះជាការខកខានក្នុងការបំពេញការងារប្រកប ដោយឯករាជ្យ និងមានវិជ្ជាជីវៈ ។ យោងតាមវិធាន ៣៥ តារីក អាប់ឌុលហាក់ ស្នើសុំអង្គជំនុំជម្រះចេញសេចក្តីព្រមានដល់មេធាវី គង់ សំអុន, អានតា ហ្គីស្សេ និង អាថឺ វែរកិន ព្រមទាំងជូនដំណឹងដល់គណៈមេធាវីរបស់មេធាវីទាំងនេះ ។ លើសពីនេះទៀត សុំឲ្យមានការស្តីបន្ទោសចំពោះការបង្ហាញនូវអ្វីមួយដែលនាំឲ្យមានការខឹងសម្បាពីសាធារណជន ។

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៣

សហមេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៉ែត ស៊ីម៉ូណូហ្វូត បានបន្ថែមថា ការលើកឡើងរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដែលបានចុះផ្សាយក្នុងការសែតនោះ គឺជាការនិយាយខុស និងមិនស្មោះត្រង់ ។ មេធាវីការពារក្តីនិយាយយកត្រូវតែខ្លួនឯង ដោយចោទប្រកាន់ថាគេបន្ទុំមិនឲ្យនិយាយ ឬរារាំងមិនឲ្យនិយាយ ។ មេធាវីការពារក្តីអាចនិយាយតទល់គ្នានៅចំពោះមុខអង្គជំនុំជម្រះបាន ដោយពុំចាំបាច់និយាយយកត្រូវតែម្នាក់ឯងចំពោះមុខអ្នកកាសែតឡើយ ។ តាមរយៈអត្ថបទកាសែតនេះ គឺជាការប្រមាថមើលងាយដល់អង្គជំនុំជម្រះ ដល់ភាគីផ្សេងៗទៀត និងមើលងាយដល់កិច្ចដំណើរការជំនុំជម្រះដែលបានប្រព្រឹត្តទៅអស់រយៈពេលជាង ២ឆ្នាំ មកនេះ ។ មេធាវី ស៊ីម៉ូណូហ្វូត បានសង្កត់ធ្ងន់ថា គោលនយោបាយទាំង៥ដែលក្រុមមេធាវីការពារក្តីចោទប្រកាន់ថា អង្គជំនុំជម្រះទើបដាក់បញ្ចូលពិភាក្សាដេញដោលនៅពេលចុងបញ្ចប់នៃសវនាការ គឺពុំត្រឹមតូវឡើយ ។ អង្គហេតុនេះត្រូវបានកំណត់យ៉ាងច្បាស់ក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីដែលចេញនៅឆ្នាំ២០១១ ហើយនៅក្នុងសវនាការ អង្គជំនុំជម្រះបានលើកឡើងជាញឹកញាប់ឲ្យភាគីសួរសង្កត់ធ្ងន់ទៅលើគោលនយោបាយទាំង ៥ នេះ ។ ដូច្នេះការចោទប្រកាន់របស់ក្រុមមេធាវីការពារក្តីគឺពុំត្រឹមត្រូវឡើយ ។ ការធ្វើដូច្នេះ មេធាវីការពារក្តីបានប៉ុនប៉ងបំបាត់ចោលនូវភាពជឿជាក់បានរបស់តុលាការតែប៉ុណ្ណោះ ។

ជាការឆ្លើយតប មេធាវី អានតា ហ្គីស្សេ បញ្ជាក់ថា ខ្លួនមិនដែលចង់ប្រមាថដល់តុលាការ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬប្រជាជនកម្ពុជាឡើយ ។ ក្នុងមានជាមេធាវីការពារក្តី គឺមានតួនាទីតំណាងឲ្យកូនក្តីរបស់ខ្លួន ។ ជាងនេះទៅទៀត អ្វីដែលបានចុះផ្សាយក្នុងកាសែតភ្នំពេញប៉ុស្តិ៍ គឺមេធាវីបានលើកឡើងរួចហើយនៅក្នុងសេចក្តីសន្និដ្ឋានដែលមាននៅក្នុងឯកសារលេខ E288/4 ។ មេធាវីបានបន្ថែមថា *«ក្នុងនាមយើងជាមេធាវីការពារក្តី យើងមិនមែនធ្វើដើម្បីបំពេញចិត្តអ្នកណាម្នាក់នោះទេ យើងត្រូវតែបង្ហាញអំពីគោលជំហរកូនក្តីរបស់យើង និងបង្ហាញអំពីគោលជំហររបស់មេធាវីការពារក្តី អ្នកណាពេញ ឬមិនពេញចិត្ត គឺជារឿងរបស់គេ ព្រោះនេះជាសវនាការជំនុំជម្រះក្តី យើងត្រូវតែធ្វើការវិភាគទៅលើឯកសារភស្តុតាង ហើយដែលភាគីនីមួយមានការវិភាគខុសៗគ្នា...»* ។ ចុងក្រោយមេធាវី អានតា ហ្គីស្សេ បញ្ជាក់ថា មេធាវី ក៏ដូចជាប្រជាជនទូទៅដែរ គឺមានសិទ្ធិក្នុងការនិយាយស្តី ។ ដូច្នេះខ្លួនប្រើសិទ្ធិនិយាយនេះតាមរយៈសារព័ត៌មាន ហើយអ្វីដែលបាននិយាយបរិហារទាំងអស់នោះ ខ្លួនធ្លាប់និយាយនៅចំពោះមុខអង្គជំនុំជម្រះរួចហើយគឺពុំមានអ្វីថ្មីនោះឡើយ ។ ដូច្នេះប្រសិនបើការនិយាយស្តីនេះនាំឲ្យមានការដាក់ទណ្ឌកម្ម នោះជារឿងគួរឲ្យសោកស្តាយបំផុត ។ មេធាវី គង់ សំអុន បានបន្ថែមថា ការណ៍ដែលតំណាងសហព្រះរាជអាជ្ញាស្នើសុំឲ្យដាក់វិន័យចំពោះក្រុមរបស់ខ្លួនថាបានបំពានវិជ្ជាជីវៈនោះ គឺពុំបានធ្វើឲ្យស្របតាមបច្ចេកទេស ឬបទដ្ឋានដែលអាចទទួលយកបានឡើយ ។

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៣

ទោះបីជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងពុំទាន់ចេញសេចក្ដីសម្រេចលើសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញានៅឡើយ ។ ក្នុងករណីអង្គជំនុំជម្រះរកឃើញថា ពិតជាមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការដូចការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា ហើយកើតចេញពីចេតនាពិតប្រាកដ នោះក្រុមមេធាវីការពារក្ដី ខៀវ សំផន ដូចបានរៀបរាប់ឈ្មោះខាងលើ អាចប្រឈមនឹងការកំណត់ថាបានប្រព្រឹត្តកំហុសវិជ្ជាជីវៈ (វិធាន ៣៥.៥ នៃវិធានផ្ទៃក្នុងរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម) ។ វិធាន ៣៨ ចែងបន្ថែមថា “សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្ម ឬ បដិសេធក្នុងការចូលរួមសវនាការ ចំពោះមេធាវីណាម្នាក់ ប្រសិនបើយល់ឃើញថាការប្រព្រឹត្តរបស់មេធាវីរូបនោះ ជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើទៅលើវៀងក្ដី ឬផ្ទុយទៅនឹងមាត្រា ២១.៣” ។

**ចាន ប្រាថ្នា**

**ពិនិត្យដោយៈ ឆាំង យុ**